**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**
លេខ ៣៧៥៧ ព.ណ.ន.គក

ថ្ងៃចន្ទ ១កើត ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២៣

**ជម្រាបជូន**
**លោកប្រធានមន្ទីរពាណិជ្ជកម្ម ខេត្តកំពត**

**កម្មវត្ថុ** ៖ សំណើសុំអញ្ជើញ **លោកប្រធាន** ចូលរួមជាកិត្តិយស និងសហការសម្របសម្រួលរៀបចំអញ្ជើញ ស្ថាប័នពាក់ព័ន្ធ ដើម្បីចូលរួមសិក្ខាសាលាផ្សព្វផ្សាយច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិកត្រូនិក ច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា និងនីតិវិធីតម្កល់លិខិតជូនដំណឹងនៃប្រតិបត្តិការដែលមានកិច្ចធានា។

តបតាមកម្មវត្ថុខាងលើ ខ្ញុំសូមជម្រាបជូន **លោកប្រធាន** ជ្រាបថា នាយកដ្ឋាននីតិកម្មនៃក្រសួងពាណិជ្ជកម្ម នឹងរៀបចំសិក្ខាសាលាផ្សព្វផ្សាយច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិកត្រូនិក ច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា និងនីតិវិធីតម្កល់លិខិតជូនដំណឹងនៃប្រតិបត្តិការដែលមានកិច្ចធានា ដើម្បីបង្កើនការយល់ដឹងអំពីខ្លឹមសារអត្ថប្រយោជន៍ សិទ្ធិ និងកាតព្វកិច្ច នានានៅក្នុងច្បាប់ជូនទៅដល់ វិស័យពាក់ព័ន្ធនានា រួមមាន ពាណិជ្ជករ(ក្រុមហ៊ុនបញ្ចាំ ឬហាងបញ្ចាំ) ជាពិសេសគ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុ និងការិយាល័យមេធាវី។ សិក្ខាសាលាខាងលើនេះនឹងប្រព្រឹត្តទៅនៅថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ២០២៣ វេលាម៉ោង ៨:០០ នាទីព្រឹក នៅក្នុងមន្ទីរពាណិជ្ជកម្មខេត្តកំពត។

ដើម្បីអនុវត្តកិច្ចការនេះទទួលបានជោគជ័យ ក្រសួងពាណិជ្ជកម្ម ស្នើ **លោកប្រធាន** ជួយសហការសម្របសម្រួលដូចខាងក្រោម៖

១- សូមអញ្ជើញ **លោកប្រធាន** ចូលរួមជាកិត្តិយស

២- ស្នើសុំធ្វើលិខិតអញ្ជើញ ពាណិជ្ជករ (ក្រុមហ៊ុនបញ្ចាំ ឬហាងបញ្ចាំ) ជាពិសេសគ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុ (មន្ត្រីឥណទាន) និងមន្ទីរសាការី ឬការិយាល័យមេធាវី សរុបចំនួន ៤០ រូប ចូលរួម។
(សូមបញ្ជាក់ការអញ្ជើញចូលរួម ០២រូប ក្នុងមួយស្ថាប័ន និងវិស័យឯកជន)

អាស្រ័យហេតុនេះ សូម **លោកប្រធាន** ចូលរួម និងសហការសម្របសម្រួលតាមការគួរ។

សូម **លោកប្រធាន** ទទួលនូវការរាប់អានពីខ្ញុំ។

**ជ.រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**
**អគ្គលេខាធិការ**

**ឃឹម សិរីវឌ្ឍ**

សូមទំនាក់ទំនង៖
នាយកដ្ឋាននីតិកម្ម ៖ ០៧៨ ៩៦៨ ២៩៦

ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារៈ (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
៚✽៛

ក្រសួងពាណិជ្ជកម្ម

## សិក្ខាសាលាផ្សព្វផ្សាយ

ច្បាប់ស្តីពីច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា និងនីតិវិធីតម្កល់លិខិតជូនដំណឹងនៃប្រតិបត្តិការដែលមានកិច្ចធានា

សិក្ខាសាលានៅ មន្ទីរពាណិជ្ជកម្មខេត្តកំពត , ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៣

| ម៉ោង | កម្មវិធី | ទទួលបន្ទុកដោយ |
|---|---|---|
| ៨:00 – ៨:៣០ | ចុះឈ្មោះចូលរួមសិក្ខាសាលា | |
| ៩:00 – ៩:0៥ | គោរពភ្លេងជាតិនៃព្រះរាជាណាចក្រកម្ពុជា | |
| ៩:0៥ – ៩:១០ | សុន្ទរកថាបើកកម្មវិធី | ថ្នាក់ដឹកនាំ ក្រសួងពាណិជ្ជកម្ម |
| ៩:១០ – ៩:១៥ | ថតរូបអនុស្សាវរីយ៍ | គណៈរៀបចំកម្មវិធី |
| ៩:២០ – ១០:00 | បទបង្ហាញស្តី<br>ច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា<br>សំណួរ-ចម្លើយ | មន្ត្រីជំនាញនៃនាយកដ្ឋាននីតិកម្ម |
| ១០:00 – ១០:១៥ | សម្រាកពិសារអាហារសម្រន់ | |
| ១០:១៥ – ១១:៣០ | បទបង្ហាញស្តី<br>ការប្រើប្រាស់ប្រព័ន្ធតម្កល់លិខិតជូនដំណឹង<br>នៃច្បាប្រតិបត្តិការដែលមានកិច្ចធានា<br>សំណួរ-ចម្លើយ | មន្ត្រីជំនាញនៃនាយកដ្ឋាននីតិកម្ម |
| ១១:៣០ – ១១:៤០ | បញ្ចប់សិក្ខាសាលា | |